00294850

ឯកសារ: D158

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 03 / 09
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| **ដាក់ជូន:** | ការិយាល័យសហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ |
| **ភាគីដាក់ឯកសារ:** | សហមេធាវីការពាររបស់ នួន ជា |
| **ភាសា:** | ភាសាអង់គ្លេស (ឯកសារដើម) និង ភាសាខ្មែរ (អត្ថបទបកប្រែ) |
| **ប្រភេទឯកសារស្នើឡើង ដោយភាគីដាក់ឯកសារ:** | សាធារណៈ: សាធារណៈ |

---

# សំណើលើកទី ១១ ស្នើសុំបើកកិច្ចស៊ើបសួរ

---

**ដាក់ឯកសារដោយ៖**

**សហមេធាវីរបស់ នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក ម៉ម ចាន់ណា

លោក Andrew IANUZZI

**ជំនួយការដោយ:**

កញ្ញា Shona GRUNDY

**ចែកចាយជូន៖**

**សហចៅក្រមស៊ើបអង្កេត**

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

**សហព្រះរាជអាជ្ញា:**

អ្នកស្រី ជា លាង

លោក Robert PETIT

**ក្រុមមេធាវីការពារទាំងអស់**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន ២១(១), វិធាន៥៥(១០) និងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (ហៅថា "វិធានផ្ទៃក្នុង") សហមេធាវីរបស់ជនត្រូវចោទ **នួន ជា** (ហៅថា"មេធាវីការពារ") សូមដាក់សំណើសុំបើកកិច្ចស៊ើបសួរនេះ ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស")។

2. យោងតាមព័ត៌មានដែលអាចរកបានជាសាធារណៈ មានការលេចឮថា ប្រធានរដ្ឋបាល អ.វ.ត.ក ត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយនៅក្នុងសាលាក្ដីនេះ។ ក្នុងខណៈដែលចរិតលក្ខណៈ និង វិសាលភាពច្បាស់លាស់នៃការប្រព្រឹត្តអំពើទុច្ចរិតល្បីរន្ទឺបែបនេះ មិនទាន់បានដឹងឮជាសាធារណៈនៅឡើយនោះ មេធាវីការពារសង្ស័យទៅលើអត្ថិភាពនៃអំពើពុករលួយក្នុងស្ថាប័នដែលមានប្រព័ន្ធរៀបចំចាត់ចែងទុកជាមុន នៅទូទាំងសាលាក្ដីនេះ ក្នុងអំឡុងពេលនៃការបន្តកិច្ចស៊ើបសួរទៅលើសកម្មភាពព្រហ្មទណ្ឌរបស់លោក **នួន ជា** ដែលត្រូវបានចោទប្រកាន់កន្លងមកនេះ។ ដើម្បីវាយតម្លៃថាតើមានផលប៉ះពាល់ខ្លាំងប៉ុណ្ណា ពីអំពើពុករលួយដែលបានចោទប្រកាន់មកលើការចាត់ចែងយុត្តិធម៌ក្នុងរយៈកាលកន្លងមកនៅ អ.វ.ត.ក នោះតម្រូវឲ្យមានការបង្ហាញឲ្យដឹងឮមួយពេញលេញ និង ប្រកបដោយតម្លាភាព។ ក្នុងន័យនេះ ទោះជាទាំងរាជរដ្ឋាភិបាលកម្ពុជា ("RGC") ឬ ទាំងអង្គការសហប្រជាជាតិ (អ.ស.ប) មិនមានឆន្ទៈជួយដល់មេធាវីការពារក៏ដោយ ក៏ពេលនេះតម្រូវឲ្យមានការស្វែងរកកិច្ចសហប្រតិបត្តិការពី ក.ស.ច.ស តែម្ដង។

3. សំណើភ្លាមៗនេះមិនមានឯកសារអ្វីជាសម្ងាត់នោះទេ។ ឯកសារយោង និងអំណះអំណាងទាំងអស់គឺជាអង្គហេតុ និងជាប្រភព ដែលអាចរកបានជាសាធារណៈទៅហើយ។ អាស្រ័យហេតុនេះ មេធាវីការពារបានកំណត់ថា ឯកសារនេះ គឺជាឯកសារសាធារណៈមួយ និងគួរត្រូវបានកំណត់ដូចគ្នានេះដែរពីសំណាក់ ក.ស.ច.ស។

## II. អង្គហេតុពាក់ព័ន្ធ

### ក. ការចោទប្រកាន់ពីអំពើពុករលួយនៅ អ.វ.ត.ក

4. ការចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុករលួយនៅ អ.វ.ត.ក ដែលមិនទាន់បានដោះស្រាយនៅឡើយនោះ បានយាយីសាលាក្ដីនេះអស់រយៈពេលជាងពីរឆ្នាំមកហើយៈ

ក. កាលពីខែមករា ឆ្នាំ២០០៧ សារព័ត៌មានជាភាសាខ្មែរឈ្មោះថា *សម្លេងយុវជនខ្មែរ* បានលើកឡើងថា ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីដទៃទៀតនៅ អ.វ.ត.ក ត្រូវបានគេតម្រូវឱ្យ "បរិច្ចាគប្រាក់បៀវត្សរបស់ខ្លួនចំនួនសាមសិបភាគរយទៅឱ្យ [គណៈបក្សប្រជាជនកម្ពុជា] ដើម្បីផ្លាស់ប្តូរយកមុខតំណែងរបស់ពួកគេនៅក្នុងសាលាក្តីនេះ[1]។

ខ. នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ សារព័ត៌មាន *ឌឹ ខែមបូឌា ដេលី* បានរាយការណ៍ថា និយោជិតជាជនជាតិកម្ពុជាម្នាក់របស់ អ.វ.ត.ក ដែលសុំមិនបញ្ចេញឈ្មោះ "បានអះអាងថា គាត់បានបង់ប្រាក់ចំនួន ២៥ ភាគរយពីប្រាក់បៀវត្សរបស់គាត់ ដើម្បីជាថ្នូរនឹងមុខដំណែងរបស់គាត់" ហើយ "និយោជិតបីនាក់ផ្សេងទៀតនៅសាលាក្តីនេះដែរ បានប្រាប់គាត់ថា ពួកគេក៏ត្រូវបង់ប្រាក់ដូចគ្នានេះផងដែរ"[2] ។

គ. នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ប្រធានរដ្ឋបាល អ.វ.ត.ក លោក ស៊ាន វិសុទ្ធ បានផ្សព្វផ្សាយនូវការជូនដំណឹងមួយទាក់ទងទៅនឹងការចោទប្រកាន់ថ្មីៗពីអំពើពុករលួយ នៅក្នុងសាលាក្តីនេះ[3]។

ឃ. នៅចុងឆ្នាំ ២០០៨ អតីតបុគ្គលិកម្នាក់របស់ អ.វ.ត.ក ដែលបាននិយាយជាអនាមិកមកកាន់ *សារព័ត៌មានភ្នំពេញប៉ុស្តិ៍* បានផ្តល់នូវការរៀបរាប់លំអិតពីអំពើពុករលួយដែលគេបានចោទប្រកាន់មកទល់នឹងថ្ងៃនោះថា: ប្រាក់បៀវត្សប្រចាំខែ "ត្រូវបានគេបើកឱ្យគ្រប់ចំនួន ប៉ុន្តែនៅពេលដែលអ្នក[បើក]ប្រាក់បៀវត្សនោះហើយ អ្នកត្រូវដាក់ប្រាក់បៀវត្សនោះចូលទៅក្នុងស្រោមសំបុត្រមួយ រួចប្រគល់ស្រោមសំបុត្រនោះទៅឱ្យអ្នកប្រមូលប្រាក់ [...]។ នៅចំពោះមុខអ្នកដទៃ គេប្រាប់អ្នកឱ្យនិយាយថា "គ្មានអ្នកណាកាត់យកប្រាក់ពីខ្ញុំទេ" [ហើយ]ប្រាក់ដែលបានបញ្ជូនទៅក្នុងគណនីយរបស់អ្នក គឺគ្រប់ចំនួន ប៉ុន្តែ ក្រោយមកអ្នកត្រូវ [...] តាមចំនួនភាគរយនោះ"[4]។

ង. នៅពេលវេលាមួយដែលមិនច្បាស់លាស់ "បុគ្គលិកសាលាក្តីម្នាក់"ដែលសុំមិនឱ្យបញ្ចេញឈ្មោះបាននិយាយមកកាន់*សារព័ត៌មានភ្នំពេញប៉ុស្តិ៍* ដោយបានរៀបរាប់លំអិតប្រហាក់ប្រហែលគ្នានេះដែរថា: "សម្រាប់រយៈពេលបួនខែដំបូងនៃ[កិច្ចសន្យារបស់ខ្ញុំ] ខ្ញុំបានបង់ប្រាក់ចំនួន ៧០ ភាគរយពី [ប្រាក់ខែរបស់ខ្ញុំ នៅក្នុងអំពើពុករលួយនោះ] ហើយក្រោយមកវាបានចុះមកនៅ

---

1 So Phal, *The Voice of Khmer Youth*, 31 January 2007, 'CPP-Appointed Judges, Prosecutors in KR Court See 30% of Their Wages Deducted' (translation); *see also* Cat Barton, *The Phnom Penh Post*, 23 February–8 March 2007, 'Kickback claims stain the KRT'.

2 Erika Kinetz, *The Cambodia Daily*, 25 September 2007, 'Report Finds Flaws in ECCC Administration'.

3 Douglas Gillison, *The Cambodia Daily*, 29 July 2008, 'ECCC Receives New Graft Allegations on Eve of Funds Drive', p 29

4 Cat Barton, *The Phnom Penh Post*, 27 February 2009, 'Tribunal graft charges spread: German delegation exposes results of secret UN probe; staff concur', p 1.

ត្រឹមដប់ (១០) ភាគរយ [...]។ ឧបមាថា លោកជាអ្នកគ្រប់គ្រង។ លោកមានមនុស្ស សាមសិប (៣០) នាក់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក។ ដូច្នេះ អ្នកដែលនៅក្រោមលោកដឹងថាត្រូវប្រគល់ស្រោមសំបុត្ររបស់ពួកគេ[ដែលមានប្រាក់សំណូកនៅក្នុងនោះ] មកឱ្យលោក ហើយលោកយកស្រោមសំបុត្រនោះទៅប្រគល់ឱ្យ លោក ស៊ាន វិសុទ្ធ។ [...] *នៅគ្រប់ផ្នែកទាំងអស់ គឺវាដូចៗតែគ្នាហ្នឹង*'[5]។ ដោយសារហេតុផល ដែលស្ថិតនៅពីខាងក្រោយអនាមិកភាពរបស់ខ្លួនដែលបានបញ្ជាក់អះអាងនោះ ប្រភពព័ត៌មានបានរៀបរាប់ពីការភ័យខ្លាចពីរ: ប្រតិឃាតអវិជ្ជមានដល់វិជ្ជាជីវៈ និង ការធ្វើឱ្យប៉ះពាល់ដល់សមាជិកគ្រួសារ[6]។

មកទល់នឹងថ្ងៃនេះ ពុំទាន់មានការចោទប្រកាន់ណាមួយ ត្រូវបានដោះស្រាយជាសាធារណៈនៅឡើយទេ។

**ខ. ប្រតិកម្មជាផ្លូវការ និង ការជឿនលឿនទៅមុខ**

5. ការឆ្លើយតបពីរាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប ធ្វើឡើងតែក្នុងរយៈពេលមិនដល់ពីរសប្តាហ៍ផង។ ចំណែកឯការស៊ើបអង្កេតឯករាជ្យជាច្រើន ដែលបានធ្វើឡើងទៅលើការដឹកនាំ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្សរបស់ អ.វ.ត.ក គឺពុំមានសវនកម្មណាមួយបានដាក់បញ្ចូលនូវអាណត្តិជាក់លាក់ដើម្បីពិនិត្យមើលលើការចោទប្រកាន់ពីអំពើពុករលួយនេះទេ[7]។ ជាការពិត នៅក្នុងខែ មករា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធសំណើមួយរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដើម្បីធានាឱ្យមានជំនួយអន្តរជាតិ ក្នុងការស៊ើបអង្កេតទៅលើការចោទប្រកាន់ទាំងនេះថាជា "មធ្យោបាយមួយធានាឱ្យមានការទុកចិត្តពីសាធារណៈជន និងអ្នកផ្តល់ជំនួយជាបន្តទៅទៀតមកឱ្យសាលាក្តីនេះ"[8] ។

6. យោងតាមស្មារតីនៃការអះអាងកាលពីខែមិថុនា ឆ្នាំ២០០៨ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានជំរាបជូនការិយាល័យកិច្ចការនីតិកម្ម អ.ស.ប (OLA) ថា កម្ពុជាមានទាំងមធ្យោបាយ និងសិទ្ធិដើម្បីដោះស្រាយការចោទប្រកាន់ទាំងនេះ ដោយមិនចាំបាច់មានការជ្រៀត

---

[5] *Ibid*, p 2 (emphasis added).

[6] *Ibid* ('I'm afraid, if they know I talk to you, they're not going to take a gun and shoot me in my face, but they will find some way [to fire me] [...] or they [will hurt] my kids. [...] Anyone who speaks, they will be terminated [...]. They will set up their committee and find a way to get rid of that person who has talked [...]'.)

[7] Erika Kinetz, *The Cambodia Daily*, 25 September 2007, 'Report Finds Flaws in ECCC Administration'; Erika Kinetz, *The Cambodia Daily*, 20 February 2008, 'Gov't Rejects UN Call to Probe ECCC', p 2; Ly Menghour, *The Mekong Times*, 28 April 2008, 'KRT hopes HR audit clears mismanagement doubts', p 5.

[8] Erika Kinetz, *The Cambodia Daily*, 20 February 2008, 'Gov't Rejects UN Call to Probe ECCC', p 1.

ជ្រែកពីអន្តរជាតិនោះឡើយ[9]។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសភ្លាមៗពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយថ្មីមួយដើម្បីទទួល និងដោះស្រាយពាក្យបណ្តឹងស្តីពីអំពើពុករលួយ ដែលបានលើកឡើងដោយបុគ្គលិករបស់សាលាក្តីនេះ[10]។ ក្នុងពេលជាមួយគ្នានោះដែរ ដោយមិនមានការជូនដំណឹងជាមុន លោក កែវ ធីរុធ ដែលជាប្រធានផ្នែកបុគ្គលិកខាងភាគីកម្ពុជានៃសាលាក្តីនេះត្រូវបានផ្លាស់ប្តូរទៅកាន់មុខដំណែងមួយនៅទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា[11]ហើយលោក ស៊ាន វិសុទ្ធ បានសន្យាលាលែងពីមុខដំណែង ប្រសិនបើរូបគាត់ត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងអំពើពុករលួយនៅក្នុង អ.វ.ត.ក មែននោះ[12]។ ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុងរបស់ អ.ស.ប (OIOS) បានធ្វើការពិនិត្យឡើងវិញជាសម្ងាត់ ("នូវការចោទប្រកាន់ជាក់ស្តែងពីអំពើពុករលួយពីសំណាក់បុគ្គលិកជនជាតិកម្ពុជាលើសពីម្នាក់ឡើងទៅ" ប្រសិនបើមិនទាន់បានបញ្ជាក់ឱ្យដឹងនៅឡើយនោះទេ)[13] ។

7. ការផ្តល់ថវិកាដែលគ្រប់គ្រងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សម្រាប់ខាងភាគីកម្ពុជានៅក្នុងតុលាការនេះ ត្រូវបានបង្អាកទាំងស្រុង នៅក្នុងខែសីហា ឆ្នាំ២០០៨ នៅពេលដែលប្រទេសអ្នកផ្តល់ជំនួយបានពិចារណាទៅលើការឆ្លើយតបរបស់ខ្លួន ចំពោះការចោទប្រកាន់ពីអំពើពុករលួយនេះ[14]។ គិតមកទល់នឹងថ្ងៃនេះ មិនទាន់មានដំណោះស្រាយណាមួយទៅលើបញ្ហានេះនៅឡើយទេ ហើយកាតព្វកិច្ចបើកប្រាក់បៀវត្សខាងភាគីកម្ពុជាសម្រាប់ខែមីនា ឆ្នាំ២០០៩ ដែលបានបំភិតបំភ័យថាមិនមានថវិកាដើម្បីបើកជូនទេនោះ[15] បានទទួលការផ្តល់ថវិកាជាបន្ទាន់មួយក្នុងរយៈពេលដប់មួយម៉ោងពីប្រទេសជប៉ុន[16]។

8. នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ លទ្ធផលពីការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុងដែលបានបង្ហាញអត្តសញ្ញាណបុគ្គលជាប់សង្ស័យពីការប្រព្រឹត្តឱ្យមានកំហុស លើសពីម្នាក់ឡើង

[9] Douglas Gillison, *The Cambodia Daily*, 9–10 August 2008, 'Government Asserts Jurisdiction Over KR Tribunal Graft Claims', p 3.

[10] Neth Pheaktra, *The Mekong Times*, 18 August 2008, 'KRT forms new anti-corruption committee', p 5.

[11] Craig Guthrie, *The Mekong Times*, 12 August 2008, 'KRT appoints new chief of troubled personnel department', p 2; Prak Chan Thul & Douglas Gillison, *The Cambodia Daily*, 12 August 2008, 'ECCC Gets New Cambodian Chief of Personnel', p 28; Douglas Gillison, *The Cambodia Daily*, 13 August 2008, 'Court: Staff Rotation Unrelated to Allegations', p 27.

[12] Neth Pheaktra, *The Mekong Times*, 18 August 2008, 'KRT forms new anti-corruption committee', p 5.

[13] Douglas Gillison, *The Cambodia Daily*, 5 August 2008, 'UN "Reviews" Claims of Graft: ECCC Official', p 1.

[14] Douglas Gillison, *The Cambodia Daily*, 6 August 2008, 'ECCC Funding Delayed Over Graft Claims', p 1; Douglas Gillison, *The Cambodia Daily*, 12 August 2008, 'KR Tribunal Donors Extend Funding Delay', p 28.

[15] Georgia Wilkins, *The Phnom Penh Post*, 3 March 2009, 'ECCC says no pay for nationals', p 1; Douglas Gillison, *The Cambodia Daily*, 3 March 2009, 'KR Judges: Salaries Hinging on UN, Gov't Talks', p 24.

[16] Douglas Gillison, *The Cambodia Daily*, 21–22 March 2009, 'Japan Fills the March Payroll for the ECCC', pp 1, 15; Georgia Wilkins, *The Phnom Penh Post*, 23 March 2009, 'Japan Supplies ECCC with $200,000', p 2.

ទៅ ត្រូវបានបញ្ជូនទៅរាជរដ្ឋាភិបាលកម្ពុជា[17]។ ប្រមាណជាងមួយខែក្រោយមក លោក Knut Rosandhaug អ្នកសម្របសម្រួលរបស់ UNAKRT បានជំរាបជូនប្រតិភូអាល្លឺម៉ង់មួយក្រុម ដែលមកធ្វើទស្សនកិច្ចថា អ.ស.ប បានស៊ើបអង្កេតទៅលើលោក ស៊ាន វិសុទ្ធ និងបានរកឃើញថា "គាត់មានទោសកំហុសនៅក្នុងអំពើពុករលួយនេះ"[18]។ លើសពីនេះទៅទៀត តាមទស្សនៈរបស់គាត់ លោក Knut Rosandhaug ហាក់បានលើកឡើងថា "អ.ស.ប គួរតែដកខ្លួនចេញពីសាលាក្ដីមួយនេះ ប្រសិនបើ រដ្ឋាភិបាលេនៅតែបន្តបដិសេធចំពោះការស៊ើបអង្កេតទៅលើការចោទប្រកាន់ពីអំពើពុករលួយតទៅទៀតនោះ"[19]។ ក្នុងរយៈពេលដ៏ខ្លីក្រោយមក លោក ស៊ាន វិសុទ្ធ បានប្រកាសពីការដើរចេញរបស់គាត់ពីសាលាក្ដីនេះទាំងមិនច្បាស់លាស់[20]។ ដោយការអះអាងទៅលើបញ្ហាដែលនៅតែបន្តពាក់ព័ន្ធទៅនឹងសុខភាព គាត់មិនទាន់បានវិលត្រឡប់មកកាន់ អ.វ.ត.ក វិញនៅឡើយទេ[21]។

9. នៅខែធ្នូ ឆ្នាំ២០០៨ រាជរដ្ឋាភិបាល និង ការិយាល័យកិច្ចការនីតិកម្ម បានចាប់ផ្ដើមធ្វើការចរចារគ្នា ដោយមានបំណងពង្រឹងយន្តការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងសាលាក្ដីនេះ ដែលនាំឲ្យទទួលបានលទ្ធផលមួយហៅថា "ការទម្លុះទម្លាយភាពទាល់ច្រក-Breakthrough" ក្នុងខែកុម្ភៈ ឆ្នាំ២០០៩: ដោយមាននីតិវិធីរាយការណ៍ស្របគ្នា ដោយសំអាងទៅលើ "រូបមន្តនៃមតិភាគច្រើនលើសលប់" របស់តុលាការ ដែលជាគោលការណ៍មូលដ្ឋាននៃដំណើរការប្រព្រឹត្តទៅរបស់ អ.វ.ត.ក[22]។

[17] Douglas Gillison, *The Cambodia Daily*, 18 September 2008, 'Gov't Receives UN Findings on KR Tribunal Graft Review', p 28; Douglas Gillison, *The Cambodia Daily*, 20–21 September 2008, 'Government: UN Review of KRT Wrong to Name Names' p 5; Georgia Wilkins, *The Phnom Penh Post*, 22 September 2008, 'KR court graft review unfairly names and shames, govt says', p 2.

[18] Bundestag Delegation, '[Draft] Report on the trip to Cambodia and Indonesia by a delegation of the Committee for Human Rights and Humanitarian Aid, 25 October–3 November 2008' (available at http://www.bundestag.de/ausschuesse/a17/reisen/ASEAN2008.pdf); *see also* Douglas Gillison, *The Cambodia Daily*, 26 February 2009, 'UN Officer Cites Gov't Meddling in Tribunal: Panel', p 1; Isabelle Roughol, *The Cambodia Daily*, 27 February 2009, 'Report Citing Gov't Meddling in ECCC Taken Off Web', p 24; Cat Barton, *The Phnom Penh Post*, 27 February 2009, 'Tribunal graft charges spread', pp 1–2; Michiel Pestman, Victor Koppe, and Andrew Ianuzzi, *The Phnom Penh Post*, 27 February 2009, 'Letter to the editor', p 6.

[19] Bundestag Delegation, '[Draft] Report on the trip to Cambodia and Indonesia by a delegation of the Committee for Human Rights and Humanitarian Aid, 25 October–3 November 2008' (available at http://www.bundestag.de/ausschuesse/a17/reisen/ASEAN2008.pdf).

[20] Douglas Gillison, *The Cambodia Daily*, 27 November 2008, 'Official: Rumors About ECCC Chief's Exit False', p 31.

[21] *Ibid*; *see also* Prak Chan Thul & Douglas Gillison, *The Cambodia Daily*, 11 February 2009, 'KR Tribunal Chief Sole Witness in Closed Probe', p 31; Cat Barton, *The Phnom Penh Post*, 27 February 2009, 'Tribunal graft charges spread: German delegation exposes results of secret UN probe; staff concur', p 2; Michiel Pestman, Victor Koppe, and Andrew Ianuzzi, *The Phnom Penh Post*, 27 February 2009, 'Letter to the editor', p 6.

[22] UN-RGC 'Joint Statement', 23 February 2009 (available at http://www.eccc.gov.kh/english/cabinet/fileUpload/108/Joint_Statement_EN.pdf); *see also* Douglas Gillison & Yun Samean, *The Cambodia Daily*, 24 February 2009, 'UN, Gov't to Split ECCC Graft Oversight', pp 1–2; Georgia Wilkins, *The Phnom Penh Post*, 24 February 2009, 'UN and govt to protect tribunal', pp 1–2.

ទោះជាយ៉ាងណាក៏ដោយ យន្តការដែលបានស្នើឡើង ដែលមិនបានផ្តល់នូវការត្រួតពិនិត្យប្រកបដោយឯករាជ្យនោះ ខកខានមិនបានបន្ធូរបន្ថយកង្វល់របស់អ្នកផ្តល់ជំនួយ ដែលមិនទាន់បានដោះស្រាយនៅឡើយនេះ និងត្រូវបានរិះគន់ដដែលៗពីសំណាក់អ្នកឃ្លាំមើលតុលាការអន្តរជាតិថាជាដំណោះស្រាយដើម្បីគ្រាន់តែលុបលាងមុខមាត់ ប៉ុន្តែ មិនមែនជាកំណែទំរង់មួយដ៏មានអត្ថន័យនោះទេ[23]។

10. ចាប់តាំងពីការចោទប្រកាន់បានលេចឡើងជាលើកទីមួយ នៅដើមឆ្នាំ ២០០៧ មក មានអង្គការ និងអ្នកធ្វើអត្ថាធិប្បាយជាច្រើន ដែលកត់សំគាល់ពីការគំរាមកំហែងដល់ជំនឿទុកចិត្ត និងឯករាជ្យភាពដែលបង្កឡើងដោយអំពើពុករលួយដ៏ទូលំទូលាយនោះ បានអំពាវនាវជាចំហរឲ្យមានការស៊ើបអង្កេត។ អង្គការ និង បុគ្គលទាំងនេះរួមមានៈ គម្រោងយុត្តិធម៌សង្គមសេរី (the Open Society Justice Initiative)[24], មជ្ឈមណ្ឌលឯកសារកម្ពុជា (the Documentation Center of Cambodia)[25], អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch)[26], គណៈកម្មធិការអឺរ៉ុប (the European Commission)[27], កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)[28], សមាគមនៃ

---

[23] Douglas Gillison, *The Cambodia Daily*, 26 February 2009, 'OSJI: Reconsider KR Tribunal Anti-Graft Measures', p 2; Georgia Wilkins, *The Phnom Penh Post*, 26 February 2009, 'Watchdog slams UN over KRT', pp 1–2; Sok Khemara, *Voice of America*, 2 March 2009, 'Some Remain Skeptical of Tribunal Corruption'.

[24] James Goldston (OSJI executive director), Press Release, 14 February 2007, 'Corruption Allegations at Khmer Rouge Court Must Be Investigated Thoroughly' (stating 'the ECCC should immediately implement further measures to combat corruption and protect the court's independence and transparency') and Press Release, 12 February 2009, 'Khmer Rouge Tribunal 's Credibility Jeopardized by Corruption and Political Interference on Eve of First Trial' (stating the ECCC 'must demonstrate that it is not a tool of the Cambodian government and ensure a fair and transparent judicial process' and 'should take aggressive action to respond to the allegations of corruption').

[25] Youk Chhang (DC-Cam director), *The Cambodia Daily*, 1 February 2008, Op-Ed, 'Provisos to US Directly Funding KR Tribunal', p 31 (calling for an independent review of the corruption allegations and for 'decisive action against any employee found to have engaged in malfeasance').

[26] Sara Colm (HRW senior researcher), *The Cambodia Daily*, 16 June 2008, Op-Ed, 'ECCC Needs Reforms First, Money Next', p 35 (noting that '[i]t is also necessary to properly address outstanding corruption allegations that have never been adequately investigated').

[27] Rafael Dochao Moreno (EC Charge d'Affaires), quoted in *The Cambodia Daily*, 1 August 2008, 'EC, UN Want Inquiry if KRT Allegations Surface', p 28 ('The EC is concerned and hopes that the ECCC will use any possible means and effort to investigate any allegations.'); James Moran (EC Asia director), quoted in *The Phnom Penh Post*, 4 March 2009, 'EC review raises KRT graft', p 1 ('There needs to be a resolution as soon as possible [to the issue of corruption], and this must be sorted out.')

[28] Unidentified UNDP spokesperson, quoted in *The Cambodia Daily*, 1 August 2008, 'EC, UN Want Inquiry if KRT Allegations Surface', p 28 ('Allegations of corruption or any misappropriation of funds are a serious matter, and if such allegations are presented and found to have merit, they should be fully investigated and appropriate action taken where required.')

បណ្តាអង្គការមិនមែនរដ្ឋាភិបាលដើម្បីយុត្តិធម៌កម្ពុជាជាច្រើន[29] រួមទាំង លោកសាស្ត្រាចារ្យ ចន ហាល (John Hall) ដែលជាអ្នកឃ្លាំមើល អ.វ.ត.ក ដ៏យូរអង្វែងផងដែរ[30]។

11. ជាការគួរឱ្យកត់សំគាល់ ចៅក្រមអន្តរជាតិបានលើកឡើងថា ពួកគាត់នឹងមិនអត់ឱនចំពោះការគំរាមកំហែងដល់ឯករាជ្យភាព និងអនាគតិភាពរបស់សាលាក្តីនេះឡើយ។ នៅដើមឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតជនជាតិបារាំងលោក Marcel LEMONDE បានបង្ហាញជំហរដ៏ម៉ឺងម៉ាត់របស់គាត់ទៅលើបញ្ហានេះថា៖

> “ចៅក្រមអន្តរជាតិបានអះអាងថា ពួកគាត់មិនអាចចូលរួមនៅក្នុងដំណើរការកាត់សេចក្តីមួយដែលមិនមែនជាការកាត់សេចក្តីប្រកបដោយយុត្តិធម៌ នៅចំពោះមុខសាលាជម្រះក្តីមួយដែលឯករាជ្យ និងអនាគតិបានទេ [...]។ “នេះជាបញ្ហាមួយដែលមិនអាចចរចារបានទេ ហើយប្រសិនបើមិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌទាំងនេះទេ នោះចៅក្រមទាំងឡាយមិនមានជម្រើសអ្វីតែក្រៅពីការស្នើសុំឱ្យ អ.ស.ប ដកខ្លួនចេញនោះទេ” [...]។ “នេះមិនមែនជាការគំរាមកំហែង ឬកាន់តែអាក្រក់ជាងនេះទៅទៀត វាមិនមែនជាការកម្លានោះទេ។ វាជាតថភាពពិត”[31]។

លោកស្រី Silvia Cartwright ជាជនជាតិញូវហ្សឺឡែន ដែលជាចៅក្រមអន្តរជាតិមួយរូបក្នុងចំណោមចៅក្រមអន្តរជាតិពីររូប នៅក្នុងអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីនេះ ហាក់ដូចជាមានប្រសាសន៍ក្នុងនាមឱ្យចៅក្រមទាំងអស់ បានសម្រេចចិត្តដូចគ្នានេះដែរថា:

> “បញ្ហាមួយក្នុងចំណោមបញ្ហាចំបងៗជាច្រើន ដែលធ្វើឱ្យចៅក្រមទាំងអស់មានកង្វល់នោះគឺអំពើពុករលួយនៅក្នុង អ.វ.ត.ក។ យើងសូមស្វាគមន៍រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីធានាថា ការចោទប្រកាន់ទាំងនេះត្រូវបានដោះស្រាយពេញលេញ និងប្រកបដោយយុត្តិធម៌ ហើយដាក់ចេញនូវវិធានការឯករាជ្យដើម្បីធានាថា [ការទាមទារទាំងអស់]ត្រូវបានដោះស្រាយនៅក្នុងលក្ខណៈមួយដែលមានតម្លាភាព។ យើងយល់ស្របថា ការកាត់សេចក្តី

[29] Joint NGO Statement, *The Phnom Penh Post*, 10 September 2008, Comment, ‘Address graft charges or jeopardize the KR tribunal’, p 6 (calling on the ECCC ‘to assure the public it has adequate mechanisms to deal with allegations of corruption in a timely and conclusive manner’).

[30] John Hall, *Far Eastern Economic Review*, 2 March 2009, ‘Judging the Khmer Rouge Tribunal’ (‘Despite years of ineffectual handwringing by the UN, donors and monitors, the ECCC has failed to adequately address persistent accusations of corruption and political interference.’); *see also* John Hall, *International Herald Tribune*, 10 March 2009, Op-Ed, ‘Trial on Trial’ (‘[T]he allegations are extremely serious and must be addressed. To this point the Cambodian authorities have routinely dismissed as “unverified” all allegations of corruption that have been brought to their attention. But now the chief Cambodian administrator at the tribunal is implicated by name in the parliamentary report of a donor nation, and that requires clear, thorough and independent review by a competent investigative body.’).

[31] Cat Barton, *The Phnom Penh Post*, 23 February–8 March 2007, ‘Kickback Claims Stain the KRT’.

ជាប្រវត្តិសាស្ត្រ ដែលមានសារៈសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជានោះ មិនត្រូវធ្វើឲ្យជាប់ប្រឡាក់ប្រឡូកជាមួយអំពើពុករលួយនោះទេ"[32] ។

ការព្រួយបារម្ភទាំងនេះត្រូវបានបន្លឺឡើងដោយលោក Richard Rogers ដែលជាប្រធានផ្នែកគាំពារការការពារក្តី (DSS) ក្នុងសុន្ទរកថាបិទរបស់គាត់ នៅឯកិច្ចប្រជុំពេញអង្គចុងក្រោយរបស់ អ.វ.ត.ក[33]។

## ខ. កិច្ចខិតខំប្រឹងប្រែងរបស់មេធាវីការពារ

12. ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៨ មក មេធាវីការពារបានខិតខំស្វែងរកដំណោះស្រាយមួយដែលមានតម្លាភាពទៅលើការចោទប្រកាន់ទាំងអស់ ដើម្បីធានាដល់សិទ្ធិរបស់លោក **នួន ជា** ក្នុងការទទួលបានកិច្ចស៊ើបសួរមួយដែលមានយុត្តិធម៌ និងការជំនុំជម្រះក្តីដែលអាចប្រព្រឹត្តទៅបាន។ កិច្ចខិតខំប្រឹងប្រែងដំបូងៗ ដើម្បីទទួលបានលទ្ធផលស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានច្រានចោលដោយ អ.ស.ប និង ភាគីកម្ពុជានៅក្នុងសាលាក្តីនេះ ដ៏ដូចជារាជរដ្ឋាភិបាលកម្ពុជាផងដែរ[34]។ កិច្ចស៊ើបសួរទៅលើការចោទប្រកាន់ ដែលផ្តួចផ្តើមបណ្តឹងដោយសហមេធាវីអន្តរជាតិរបស់លោក **នួន ជា** កាលពីខែមករា ឆ្នាំ២០០៩[35] កន្លងទៅនេះ ត្រូវបាន

---

[32] Douglas Gillison, *The Cambodia Daily*, 2 September 2008, 'ECCC Judges Meet To Discuss Trial Procedures', p 2.

[33] 'DSS: Press Statement', 6 March 2009 ('The DSS welcomes the statement by the international judges affirming their concern about unresolved allegations of corruption within the ECCC. This reinforces their position at the last Plenary that kick-back allegations must be dealt with "fully and fairly [...] and in a transparent manner" and will be a comfort to all those who fear that the administration of justice within the ECCC may fall prey to political compromise.')

[34] 19 September 2008 letter from Nuon Chea Defence Team to Sean Visoth and Knut Rosandhaug (seeking confidential disclosure of the OIOS report and related correspondence); 20 October 2008 letter from Knut Rosandhaug to Nuon Chea Defence Team (invoking the UN's privileges and immunities with respect to the requested documentation); 24 October 2008 letter from Sean Visoth to Nuon Chea Defence Team (denying knowledge/custody of the requested documentation); and 31 October 2008 letter from Michiel Pestman and Victor Koppe to Sok An (requesting disclosure of the same material by the RGC). *N.B.* No reply was ever received from Sok An. *See also* Douglas Gillison, *The Cambodia Daily*, 25 September 2008, 'Nuon Chea Team: Alleged Graft at ECCC Could Harm Fairness', p 24; Georgia Wilkins, *The Phnom Penh Post*, 25 September 2008, 'Graft could taint trials at the KRT: defense lawyers', p 3; Douglas Gillison, *The Cambodia Daily*, 29 October 2008, 'Nuon Chea Team Barred Access to Graft Charges', p 27; Douglas Gillison, *The Cambodia Daily*, 7 November 2008, 'Nuon Chea Team Asks Sok An for Graft Findings', p 29; Georgia Wilkins, *The Phnom Penh Post*, 7 November 2008, 'Defence lawyers urge Sok An to hand over KRT corruption info', p 3.

[35] Criminal Complaint No 44-09-01-2009, filed by Michiel Pestman, Victor Koppe, and Andrew Ianuzzi with the Office of the Royal Prosecutor attached to the Phnom Penh Municipal Court; *see also* Phorn Bopha & Katie Nelson, *The Cambodia Daily*, 9 January 2009, 'Nuon Chea Defence Submits Graft Complaint', p 29; Cat Barton, *The Phnom Penh Post*, 9 January 2009, 'KRT staff targeted by lawyers', p 1; Prak Chan Thul & Douglas Gillison, *The Cambodia Daily*, 13 January 2009, 'Municipal Court Starts ECCC Corruption Inquiry', p 28; Prak Chan Thul & Douglas Gillison, *The Cambodia Daily*, 21 January 2009, 'Nuon Chea Lawyer Called

បញ្ចប់យ៉ាងរួសរាន់ និងមុនកាល ដោយព្រះរាជអាជ្ញាអមសាលាដំបូងក្រុងភ្នំពេញ[36] បន្ទាប់ពីលោក ស៊ាន វិសុទ្ធ បាននង្ហាញអត្ថបទច្បាប់ចម្លងនៃសវនកម្មលើធនធានមនុស្សមិនច្បាស់លាស់ ដូចបានលើកឡើងខាងលើរួចមក[37]។ ពាក្យបណ្ដឹងនេះត្រូវបានប្ដឹងឧទ្ធរណ៍ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[38] ដែលត្រូវបានជូនដំណឹងជាមុននាពេលថ្មីៗ ពីការលើកឡើងរបស់លោក Rosandhaug ទាក់ទងនឹងការស៊ើបអង្កេតរបស់ អ.ស.ប[39] មកលើលោក ស៊ាន វិសុទ្ធ។ ទោះជាយ៉ាងណាក្ដី មេធាវីការពារបានសរសេរលិខិតទៅកាន់លោក បាន គីមូន (Ban Ki-moon) អគ្គលេខាធិការ អ.ស.ប ស្នើសុំឱ្យបោះបង់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ អ.ស.ប ដែលបានអះអាងទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង ព្រមទាំងលិខិតឆ្លើយឆ្លងពាក់ព័ន្ធដទៃទៀត[40]។ ក្នុងខណៈដែលកិច្ចខិតខំប្រឹងប្រែងរបស់មេធាវីការពារមកទល់នឹងសព្វថ្ងៃនេះទទួលបានការគាំទ្រពីអង្គភាពគាំពារការការពារក្ដី[41] ចៅក្រមកម្ពុជានៃ អ.វ.ត.ក បែរជាបានគំរាមកំហែងចាត់វិធានការតាមផ្លូវច្បាប់មកលើមេធាវីអន្តរជាតិទៅវិញ[42]។

## III. ច្បាប់ពាក់ព័ន្ធ

### ក. សំណើសុំបើកកិច្ចស៊ើបសួរ

in Kickbacks Probe', p 29; Georgia Wilkins, *The Phnom Penh Post*, 21 January 2009, 'Probe "will not interrupt KRT"', p 3; Georgia Wilkins, *The Phnom Penh Post*, 23 January 2009, 'KRT lawyer called to municipal court'; Phann Ana & Douglas Gillison, *The Cambodia Daily*, 4 February 2009, 'Witnesses Summoned in City's ECCC Kickback Investigation', p 30; Georgia Wilkins, *The Phnom Penh Post*, 4 February 2009, 'Corruption probe to continue, but joint sessions inconclusive'.

36 Order to File Without Processing, 5 February 2009; *see also* Douglas Gillison & Prak Chan Thul, *The Cambodia Daily*, 7–8 February 2009, 'Phnom Penh Court Halts ECCC Investigation', pp 1, 11; Georgia Wilkins, *The Phnom Penh Post*, 9 February 2009, 'Defence lawyers condemn halt of KR tribunal probe', p 3.

37 Prak Chan Thul & Douglas Gillison, *The Cambodia Daily*, 11 February 2009, 'KR Tribunal Chief Sole Witness in Closed Probe', pp 1, 31.

38 Douglas Gillison & Prak Chan Thul, *The Cambodia Daily*, 20 February 2009, 'Nuon Chea Team to Pursue Graft Inquiry at Court', p 29;

39 Bethany Lindsay & Phorn Bopha, *The Cambodia Daily*, 4 March 2009, 'Nuon Chea Lawyers Seek Inquiry Into Report', p 21.

40 23 February 2009 and 4 March 2009 letters from Michiel Pestman, Victor Koppe, and Andrew Ianuzzi to Ban Ki-moon; *see also* Douglas Gillison, *The Cambodia Daily*, 25 February 2009, 'Nuon Chea Lawyers Ask UN Chief for ECCC Graft Report', p 26; Georgia Wilkins, *The Phnom Penh Post*, 25 February 2009, 'KRT lawyers call to Ban Ki-moon', p 2.

41 Douglas Gillison & Prak Chan Thul, *The Cambodia Daily*, 17–18 January 2009, 'KR Defence Chief: Judges Put Fairness at Risk', pp 1–2; Georgia Wilkins, *The Phnom Penh Post*, 19 January 2009, 'KRT defence supports probe', p 3.

42 Katie Nelson & Phorn Bopha, *The Cambodia Daily*, 10–11 January 2009, 'ECCC Judges Threaten Legal Action Over Kickback Claims', p 5; Cat Barton, *The Phnom Penh Post*, 12 January 2009, 'KRT judges threaten lawsuit', p 2.

13. មេធាវីការពារ សូមដាក់បញ្ចូលសារណា ដែលមាននៅក្នុងសំណើមុនៗរបស់ខ្លួនក្នុងការស្នើសុំឱ្យមានការបើកកិច្ចស៊ើបសួរ[43]។ [លើសពីនេះទៀត ក.ស.ច.ស ត្រូវបានប្រគល់អំណាចយ៉ាងជាក់លាក់ឱ្យស្វែងរកព័ត៌មាន និងជំនួយការពី [...] អង្គការសហប្រជាជាតិ[44]]។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានរកឃើញនាពេលថ្មីៗនេះថា "សំណើសុំឱ្យបើកកិច្ចស៊ើបសួរនានា គួរតែបកស្រាយថា ជាសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើសកម្មភាព ឬអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក ឬនគរបាលយុត្តិធម៌ធ្វើសកម្មភាព ក្រោយពីទទួលបានការធ្វើប្រតិភូកម្មអំណាចរួចមក ដោយមានគោលបំណងប្រមូលយកព័ត៌មានដែលនាំឱ្យឈានដល់ការស្វែងរកការពិត"[45]។ លើសពីនេះទៅទៀត នៅក្នុងសេចក្ដីសម្រេចដូចគ្នានេះដែរ អ.ប.ជ បានទទួលស្គាល់ពីតម្រូវការជាបន្ទាន់ "ដើម្បីធានាថា ដំណើរការនីតិវិធីក្នុងអំឡុងពេលស៊ើបសួរមានភាពយុត្តិធម៌"[46]។

## ខ. ឯករាជ្យភាព និង ភាពឥតលំអៀង

14. យោងតាមកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក លោក **នួន ជា** មានសិទ្ធិទទួលរងការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះក្ដីដោយតុលាការមួយដែលឯករាជ្យ និងឥតលំអៀង ដូចដែលបានចែងនៅក្នុងកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលប្រទេសកម្ពុជាជាភាគីមួយនៃកតិកាសញ្ញានេះ[47]។ ជាការពិតហើយ មានតុលាការជាច្រើន ដែលត្រូវបានវាស់វែងជាចាំបាច់ដោយបទដ្ឋាននានា ដែលអាចអនុវត្តបានចំពោះមន្ត្រីទាំងឡាយដែលជាសមាជិកនៃតុលាការទាំងនោះ។ ចំនុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុត្តិសាស្ត្រពាក់ព័ន្ធ ដែលតម្រូវឱ្យចៅក្រមបំពេញសកម្មភាព និងឱ្យគេមើលឃើញថា បានបំពេញសកម្មភាពដោយឯករាជ្យ និង ឥតលំអៀង[48]។ សនិទានភាពស្ថិតនៅពីក្រោយនិយាមអន្តរជាតិនេះ អនុវត្តឱ្យអស់ពីសមត្ថភាពរបស់មន្ត្រីជាន់ខ្ពស់របស់តុលាការ ជាពិសេស តុលាការដែលជំនុំជម្រះលើបទឧក្រិដ្ឋកម្មសង្គ្រាមដែលស្មុគ្រស្មាញ

---

[43] Document Nos D-101, 'Third Request for Investigative Action', 18 August 2008, paras 6–8; D-102, 'Fourth Request for Investigative Action', 27 August 2008, paras 5–6; D-105, 'Fifth Request for Investigative Action', 26 September 2008, para 7; D-113, 'Sixth Request for Investigative Action', 30 October 2008, para 6; D-122, 'Seventh Request for Investigative Action', 1 December 2008, para 5; and D-126, 'Eighth Request for Investigative Action', 22 January 2009, para 5.

[44] Rule 55(5)(c).

[45] Document No A-190/I/20, Pre-Trial Chamber, Public 'Decision on Khieu Samphan's Appeal against the Order on Translation Rights and Obligations of the Parties', 20 February 2009, para 28.

[46] *Ibid*, para 36.P

[47] ICCPR, Article 14(1); *see also* ECCC Agreement, Articles 3(3), 5(3), 6(3), 12(2), and 13(1); ECCC Law, Articles 10 new, 19, 25, and 33 new; and Document No C-11/21, 'Urgent Application for Disqualification of Judge Ney Thol', 29 January 2008, para 10.

[48] *See* Document No C-11/21, 'Urgent Application for Disqualification of Judge Ney Thol', 29 January 2008, paras 11, 16–20.

ដែលស្ថាប័នទាំងនោះពឹងពាក់អាស្រ័យ និងទំនាក់ទំនងគ្នាទៅវិញទៅ មកជាច្រើនទទួលរ៉ាប់រង កិច្ចការសើបខុសៗគ្នាជាច្រើន ដែលកិច្ចការខ្លះក្នុងចំណោមកិច្ចការទាំងនេះអាចនឹងប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី។ ការវាយតម្លៃក្នុងបរិបទបែបនេះ គឺសំខាន់ណាស់ក្នុងការធានាដល់សិទ្ធិក្នុងការការពារ "ឲ្យមានសារៈប្រយោជន៍ និងមានប្រសិទ្ធិភាព" ជាជាង សិទ្ធិទាំងឡាយដែលមានតែក្នុង"ទ្រឹស្តី ឬមានតែឈ្មោះ"[49]។ ដូចដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានរក្សារជំហរជាយូរមកហើយថា "នៅក្នុងសង្គមប្រជាធិបតេយ្យមួយ វាមានសារៈសំខាន់ជាមូលដ្ឋានថា តុលាការត្រូវញ៉ាំងឲ្យមានជំនឿទុកចិត្តពីសាធារណៈជន ហើយលើសពីអ្វីៗទាំងអស់ គឺជំនឿទុកចិត្តពីជនជាប់ចោទ នៅពេលណាមានការជាប់ពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌ"[50] ។

## គ. ការិយាល័យរដ្ឋបាល

15. យោងតាមច្បាប់ "បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា *ត្រូវគ្រប់គ្រងដោយការិយាល័យរដ្ឋបាលមួយ*"[51] ដែលប្រធានការិយាល័យរដ្ឋបាល "ត្រូវតែជាមនុស្សមានចរិតលក្ខណៈ ស្មារតី និងសុច្ចរិតភាពខ្ពស់"[52]។ ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធាន ការិយាល័យរដ្ឋបាលត្រូវៈ

ក. "ជួយគាំទ្រដល់ការបំពេញការងាររបស់អង្គជំនុំជម្រះ ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត [...] និងត្រូវទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងការផ្តល់សេវាកម្មរបស់ស្ថាប័នទាំងនោះ"[53] ។

ខ. "ទទួលខុសត្រូវចំពោះសសុវត្ថិភាពរបស់ អ.វ.ត.ក"[54] ។

គ. "ទទួលខុសត្រូវចំពោះ [...] បច្ចេកវិទ្យាព័ត៌មាន [...] របស់ អ.វ.ត.ក"[55] ។

ឃ. "ថែរក្សាមូលដ្ឋានទិន្នន័យ ដែលមានឯកសារថតចម្លងនៃគ្រប់សំណុំរឿងស៊ើបអង្កេតបឋម កិច្ចស៊ើបសួរ និងរឿងក្តីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ" និង "ត្រូវធានាថា

---

[49] *See, e.g.*, *Artico v Italy*, ECHR App No 6694/74, 'Judgment', 13 May 1980, para 33 ('[T]his is particularly so of the rights of the defence in view of the prominent place held in a democratic society by the right to a fair trial, from which they derive.')

[50] *Panovits v Cyprus*, ECHR App No 4268/04, 'Judgment', 11 December 2008, para 94 (emphasis added); *see also* Document No C-11/21, 'Urgent Application for Disqualification of Judge Ney Thol', 29 January 2008, para 11 (citing jurisprudence of the European Court of Human Rights).

[51] ECCC Law, Article 30 (emphasis added).

[52] ECCC Law, Article 31 new.

[53] Rule 9(1); *see also* ECCC Agreement, Article 8(1) ('There shall be an Office of Administration to service the Extraordinary Chambers, the Pre-Trial Chamber, the co-investigating judges and the Prosecutors' Office.')

[54] Rule 9(2).

[55] Rule 9(3).

ឯកសារចម្លងទាំងនេះផ្តល់ទៅឲ្យតែភាគីក្តី អ្នកជំនាញ ឬបុគ្គលណាម្នាក់ដែលទទួលបាន ការអនុញ្ញាតតែប៉ុណ្ណោះ"[56] ។

ង. "ជួយដល់ក្រឡាបញ្ជី [...] ក្នុងការចាត់ចែងផ្ញើដីកាកោះ និង ការជូនដំណឹងអំពីដីកាផ្សេងៗ"[57]។

ច. "ទទួលខុសត្រូវក្នុងការថែរក្សាទុក និងការរក្សាសុវត្ថិភាពដល់ភស្តុតាង ដែលរួមមានវត្ថុតាង កំណត់ហេតុផ្តល់ចម្លើយ និងឯកសារទាំងឡាយ ដែលទទួលបានក្នុងពេលស៊ើបអង្កេតបឋម ពេលស៊ើបសួរ ពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងនៅអង្គជំនុំជម្រះតុលាការកំពូល[58], និង

ឆ. ទទួលខុសត្រូវក្នុងការសម្របសម្រួលការបណ្តុះបណ្តាលដល់បុគ្គលិករបស់ អ.វ.ត.ក និង ជួយ គាំទ្រដល់ការបណ្តុះបណ្តាលរបស់អង្គភាពយុត្តាធិការ[59]។

ដើម្បីសម្រេចបានការទទួលខុសត្រូវខុសៗគ្នាទាំងនេះ ការិយាល័យរដ្ឋបាលមានអំណាចតាមផ្លូវច្បាប់ទៅលើផ្នែកផ្សេងៗទាំងប្រាំបួននៃសាលាក្តីនេះ រួមទាំង ផ្នែកគ្រប់គ្រងតុលាការផងដែរ[60]។ ផ្នែកមួយដ៏ធំរបស់ អ.វ.ត.ក ដែលមានបុគ្គលិកជាច្រើននោះគឺ ផ្នែកគ្រប់គ្រងតុលាការ ដែលមានភារកិច្ចទទួលខុសត្រូវទៅលើកិច្ចការសំខាន់ៗ និងគួរឲ្យសើបជាច្រើន រួមមាន ការឧបត្ថម្ភគាំទ្រដល់សាក្សី និងអ្នកជំនាញការគ្រប់គ្រងក្រឡាបញ្ជី ការថែរក្សាទុកភស្តុតាង ការថែរក្សាទុកនូវការកត់ត្រា និងឯកសារផ្សេងៗ ព្រមទាំង ការសម្របសម្រួលលើការបកប្រែជាសំណេរ និងផ្ទាល់មាត់[61]។

## ឃ. គោលការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

16. ជាគោលការណ៍ ទាំង អ.ស.ប. និងទាំងរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ពីភាពអន្តរាយដោយអំពើពុករលួយមកលើស្ថាប័នប្រជាធិបតេយ្យ។ បុព្វកថានៃអនុសញ្ញាប្រឆាំងនឹងអំពើពុករលួយរបស់ អ.ស.ប (ហៅថា "អនុសញ្ញា") ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នកាលពីថ្ងៃទី៥ ខែ

---

[56] Rule 9(5).
[57] Rule 9(5).
[58] Rule 9(6).
[59] Rule 9(7).
[60] *See* 'Organizational Chart of the ECCC' (available at http://www.unakrt-online.org/Links-Logos-Thumbs/Organizational%20Chart-English.pdf). The eight other sections are Budget and Finance, DSS, General Services, Information and Communication Technologies, Personnel, Public Affairs, Security and Safety, and the Victims Unit. *N.B.* The DSS is 'autonomous with regard to the substantive defence matters set out in' Rule 11.
[61] *Ibid.*
[61] *Ibid.*

សីហា ឆ្នាំ២០០៧ លើកឡើងពីភាពធ្ងន់ធ្ងរនៃចំណោទបញ្ហា និងការគំរាមកំហែងបង្កឡើងដោយអំពើពុករលួយចំពោះ[...]នីតិរដ្ឋ[62]។ នៅក្នុងអារម្ភកថានៃអនុសញ្ញានេះ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិលោក Kofi Annan បានបកស្រាយថាអំពើពុករលួយគឺជា "ជំងឺឆ្លងដ៏កាចសាហាវមួយ 'an insidious plague'" [...] "ដែលផលប៉ះពាល់ដ៏ធ្ងន់ធ្ងររបស់វា [...] បង្កឲ្យអន្តរាយដល់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ"[63] ។ ចាប់តាំងពីពេលចូលកាន់មុខដំណែងសព្វថ្ងៃរបស់គាត់មក លោក Ban Ki-moon បានមានប្រសាសន៍ជាហូរហែរអំពីការពោលអះអាងរបស់អ្នកកាន់មុខដំណែងមុនបន្ទាប់របស់គាត់ដែលមានប្រសាសន៍ថា: អំពើពុករលួយគឺជាឧបសគ្គរារាំងដល់សិទ្ធិមនុស្ស និងនីតិរដ្ឋ។ ចំណែក ឯកឧត្តម សុខ អាន ដែលជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក៏បានយល់ដូចគ្នា ដោយមានប្រសាសន៍ថា: "រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថា អំពើពុករលួយបង្កនូវការគំរាមកំហែង [...] ដល់ស្ថាប័នប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិ និងសេរីភាពជាមូលដ្ឋាន [...]។ វាក៏បានបង្កឲ្យមានការធ្វើសេចក្តីសម្រេចចិត្តមួយមិនសមហេតុសមផលផងដែរ [...]។ បញ្ហាគឺមិនស្ថិតនៅត្រង់ថាតើគួរប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឬយ៉ាងណានោះទេ តែផ្ទុយទៅវិញ ថាតើត្រូវប្រយុទ្ធប្រឆាំងអំពើនេះដោយរបៀបណា និង ដោយមធ្យោបាយណាខ្លះទៅវិញនោះទេ"[64] ។

## IV. ឧឡារិករណ៍

### ក. គោលបំណងនៃសំណើនេះគឺ: ដើម្បីប្រមូលព័ត៌មានឈានឆ្ពោះទៅកាន់បញ្ជាក់អះអាងពីសច្ចៈភាព នៅ អ.វ.ត.ក

17. យោងតាមអង្គហេតុនានាដែលអាចរកបានជាសាធារណៈ ដូចបានលើកឡើងខាងលើ ជាពិសេសការបង្ហាញឲ្យឃើញនាពេលថ្មីៗ ទាក់ទងទៅនឹងកិច្ចស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង វាហាក់ដូចជាថា សាលាជម្រះក្តីនេះអាចត្រូវបានធ្វើឲ្យប្រឡាក់ប្រឡូកដោយអំពើពុករលួយជាស្ថាប័ន ដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុន។ នៅក្នុងដំណាក់កាលនេះ មេធាវីការពារអាចគ្រាន់តែងឿងឆ្ងល់ពីវិសាលភាពនៃអំពើទុច្ចរិត និងលទ្ធផលនៃសេចក្តីសម្រេចមិនត្រឹមត្រូវ

[62] Convention, p 5 (available at http://www.unodc.org/documents/treaties/UNCAC/Publications/Convention/08-50026_E.pdf).

[63] *Ibid*, p iii.

[64] 'Governance Action Plan', speech by Sok An, Senior Minister, Minister in charge of The Office of the Council of Ministers, and Chairman of the Council for Administrative Reform Consultative Group Meeting, Phnom Penh, 19–21 June 2002 (available at http://www.camnet.com.kh/ocm/government/government126.htm).

និង/ឬ "មិនសមហេតុផល" ដែលធ្វើឡើងដោយបុគ្គលិក អ.វ.ត.ក មកលើទង្វើខុសឆ្គងបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ ការចោទប្រកាន់ដែលត្រូវបានរាយការណ៍មកទល់នឹងសព្វថ្ងៃនេះ ដោយមានការប៉ាន់ប្រមាណសើៗ បានលើកឡើងថា បុគ្គលិកទាំងអស់នៅក្នុងការិយាល័យរដ្ឋបាល និងប្រហែលជាលើសពីនេះទៅទៀតផង អាចបានចូលរួមពាក់ព័ន្ធតាមលក្ខណៈវិជ្ជាជីវៈ ហើយជាលទ្ធផលបង្កឲ្យខូចខាតដល់សាលាជម្រះក្ដីនេះ *អាច*មានភាពអាក្រក់ប្រហាក់ប្រហែលគ្នានេះ។ អាស្រ័យហេតុនេះ មេធាវីការពារស្វែងរកនូវ "ការប្រមូលព័ត៌មានដែលនាំឆ្ពោះទៅដល់ការបញ្ជាក់អះអាងពីសច្ចភាព"នៅក្នុងសាលាជម្រះក្ដីនេះ ជាពិសេស ដើម្បីកំណត់ថាតើ អ.វ.ត.ក អាចមានលទ្ធភាពផ្ដល់ជូនយុត្តិធម៌ ដែលស្របទៅនឹងបទដ្ឋានអន្តរជាតិស្ដីពីភាពត្រឹមត្រូវដែរឬយ៉ាងណា[65]។ ដោយសារថា ទាំង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជាមិនមានឆន្ទៈជួយដល់កិច្ចស៊ើបសួរនេះ នាពេលនេះមេធាវីការពារសូមស្នើឲ្យ ក.ស.ច.ស ដែលមានយុត្តាធិការស្របច្បាប់ ពិចារណាលើសំណើស្ដីពីៈ អំណាចស្របច្បាប់ និងមធ្យោបាយនានាដើម្បីទទួលបានការស្វែងរកបែបនេះ ក្រោយពីទទួលបានព័ត៌មានរួចមក និងកាតព្វកិច្ចតាមផ្លូវសីលធម៌ដើម្បីធានាឲ្យមានភាពត្រឹមត្រូវនៃដំណើរការនីតិវិធី តែនេះមិនមែនជាចំនុចចុងក្រោយបង្អស់នៅឡើយនោះទេ។

### ខ. អំពើពុករលួយដែលរីករាលដាលជាស្ថាប័ន អាចគំរាមកំហែងដល់សិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការចោទប្រកាន់ ការស៊ើបអង្កេត និងការជម្រះក្ដីមួយដែលឯករាជ្យ និងឥតលំអៀង

18. ការចោទប្រកាន់ពីអំពើពុករលួយរីករាលដាល ដែលមិនទាន់បានដោះស្រាយនៅឡើយនៅក្នុង អ.វ.ត.ក បណ្ដាលឲ្យមានការមន្ទិលសង្ស័យមកលើសុច្ចរិតភាពជាស្ថាប័ននៃសាលាជម្រះក្ដីនេះ។ ក្រៅពីការប្រព្រឹត្តបទល្មើសមួយនៅក្រោមច្បាប់កម្ពុជា ជនទាំងឡាយណាដែលបានទាមទារ និង/ឬ ផ្ដល់ប្រាក់កាសដើម្បីប្ដូរយកការងារ គឺមិនមានសុច្ចរិតភាពដែលតម្រូវ និងធានាឲ្យមានភាពត្រឹមត្រូវនៃដំណើរការនីតិវិធីនេះបានទេ។ ប្រសិនបើ បុគ្គលិកទាំងឡាយទទួលបានការប្រគល់ភារកិច្ចគួរឲ្យរសើប មានបំណងចូលរួមពាក់ព័ន្ធនៅក្នុងអំពើពុករលួយ នោះបុគ្គលទាំងនោះអាចមានឆន្ទៈធ្វើតាមការបង្គាប់បញ្ជាដែលមិនត្រឹមត្រូវដូចគ្នានេះដែរ ដូចជា ការប្រើប្រាស់ភស្តុតាងមិនត្រឹមត្រូវ ដើម្បីគាំទ្រដល់លទ្ធផលនយោបាយដែលបានគិតទុកជាមុន។ កាន់តែល្អិតល្អន់ជាងនេះទៅទៀត

[65] Ultimately, the 'truth' of the allegations set forth in the Introductory Submission is inextricable from the probity of those charged with searching for it.

គឺដោយសារតែការ "ទិញ និងការចំណាយ" ពួកគេអាចមានអារម្មណ៍ថា ជាប់កាតព្វកិច្ចក្នុងការបំពេញមុខងារផ្លូវការរបស់ខ្លួន ទៅតាមការរំពឹងទុកជាក់ស្តែង ឬដែលបានដឹងជាមុនពីអ្នកដែលបើកប្រាក់ឲ្យពួកគេ។ ជាការពិតណាស់ អំពើពុករលួយគឺជាមធ្យោបាយដ៏ធំក្នុងការអនុវត្តការត្រួតត្រាទៅលើអ្នកចូលរួមសម្របសម្រួលជាចាំបាច់ជាមួយអំពើនេះ ដោយសារថា អំពើពុករលួយគឺជាប្រភពនៃការទទួលបានប្រភពចំណូលមិនស្មោះត្រង់មួយ។ ដោយមិនគិតពីហេតុផលជំរុញអ្វីទាំងអស់ លទ្ធផលដែលជាប់ប្រឡាក់ប្រឡូកជាមួយអ្នកបំរើការងារនៅទីនេះ គឺជាការមិនស៊ីសង្វាក់គ្នាយ៉ាងសម្បើមជាមួយនឹងសញ្ញាណនៃឯករាជ្យភាពតុលាការ និងស្ថាប័ន។

19. ការិយាល័យរដ្ឋបាល ដែលបានទទួលអាណត្តិការងារឲ្យ "ជួយគាំទ្រ" "ផ្តល់សេវា" និង"គ្រប់គ្រង" អង្គជំនុំជម្រះនានា ក.ស.ច.ស និង ក.ស.ព មួយផ្នែកនោះ គឺទទួលខុសត្រូវជាចាំបាច់ចំពោះការចាត់ចែងតុលាការនេះ។ ហើយគេបានដឹងយ៉ាងច្បាស់ថា ចៅក្រមនៅសាលាជម្រះក្តីទាំងឡាយដូចជា អ.វ.ត.ក មិនមែនបំពេញការងាររបស់ពួកគាត់តែឯងនោះទេ។ ផ្ទុយទៅវិញ នៅក្នុងការអនុវត្តមុខងារតុលាការរ ជួនកាល ចៅក្រមទាំងនោះ ត្រូវបានអ្នកជំនាញជាច្រើនជួយបំពេញកិច្ចការទៅតាមពេលវេលាមួយជាកំណត់។ ជាការពិត សម្ភារៈបរិក្ខារទាំងអស់ដែលចៅក្រមត្រូវការភ្លាមៗ ត្រូវបាន"ចាត់ចែងជាមុន"ទៅតាមយន្តការរដ្ឋបាលតុលាការ។ និយាយម្យ៉ាងវិញទៀត ឯករាជ្យភាព និងភាពឥតលំអៀងរបស់ចៅក្រម គឺជាប់ទាក់ទងគ្នាយ៉ាងស្អិតរមួតទៅនឹងឯករាជ្យភាព និងភាពឥតលំអៀងរបស់អ្នកទាំងឡាយណាដែលជួយដល់ពួកគាត់។ ហេតុដូច្នេះហើយ ការប្រគល់កិច្ចការរសើបៗ ដូចដែលបានលើកឡើងខាងលើ (នៅត្រង់កថាខណ្ឌ ១៥) ទៅឲ្យមន្ត្រីទាំងទាំងឡាយដែលមិនមានឯករាជ្យភាព និងដែលមានភាពលំអៀង អាចធ្វើឲ្យអន្តរាយដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី។ ឧទាហរណ៍:

ក. មន្ត្រីច្បាប់ អ្នកស៊ើបអង្កេត ឬក្រឡាបញ្ជី ដែលបានទទួលប្រតិភូកម្មអំណាចតុលាការមួយផ្នែកណានោះ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យរដ្ឋបាល អាចទទួលយកដោយចេតនានូវសេចក្តីសម្រេចមិនត្រឹមត្រូវ ដែលផ្ទុយទៅនឹងផលប្រយោជន៍របស់មេធាវីការពារក្តី ដូចជា ការផ្តល់យោបល់ជំទាស់ទៅនឹងសំណើស្របច្បាប់ស្នើសុំឲ្យបើកកិច្ចស៊ើបសួរ ការខកខានមិនបានស្វែងរកភស្តុតាងដោះបន្ទុកពីប្រភពដែលបានដឹង ឬ ការសហការជាមួយភាគីរដ្ឋប្បវេណី ដែលវៀចវេរ។

ខ. មន្ត្រីសំណុំរឿងអាចប្រឌិត កែប្រែ ធ្វើឲ្យច្រលំ និង/ឬ បំផ្លាញភស្តុតាង ដែលជាប្រយោជន៍ដល់មេធាវីការពារ។

គ. បុគ្គលិកផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា អាចលួចមើល និងបញ្ជូនព័ត៌មានអេឡិចត្រូនិកសម្ងាត់ ដូចជា ការណែនាំរបស់កូនក្តី ឬ ទិន្នផលការងាររបស់មេធាវីការពារទៅឱ្យ ក.ស.ព ឬបដិភាគីផ្សេងទៀត។

ឃ. អ្នកបកប្រែសំណេរ និងអ្នកបកប្រែផ្ទាល់មាត់ អាចលុបចោលភស្តុតាងដោះបន្ទុកពីឯកសារដែលបានបកប្រែជាសំណេរ ឬបកប្រែសក្ខីកម្មដែលមានប្រយោជន៍ដល់មេធាវីការពារឱ្យខុសដោយចេតនា។

ង. អ្នកចាត់ចែងសាក្សីអាចណែនាំមិនត្រឹមត្រូវ ឬមានចេតនាប្រើឥទ្ធិពលទៅលើសាក្សី និងអ្នកជំនាញ ដើម្បីឱ្យផ្តល់សក្ខីកម្មក្លែងក្លាយប្រឆាំងនឹងមេធាវីការពារ។

ច. សន្តិសុខ អ្នកបោសសំអាត ឬបុគ្គលិកកំទេចកាកសំណល់ ដែលអ្នកទាំងអស់នេះអាចមានលទ្ធភាព ច្រើនក្នុងការទទួលបានឯកសារសម្ងាត់របស់មេធាវីការពារនោះ អាចអាន ឬថតចម្លងឯកសារ និងបញ្ជូនព័ត៌មានរសើបទៅឱ្យអ្នកដែលមិនមានសិទ្ធិមើលព័ត៌មាននេះ។

ការរំលោភបំពានណាមួយក្នុងចំណោមការរំលោភបំពានទាំងនេះ អាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់រឿងក្តីរបស់លោក **នួន ជា** និងដកហូតសិទ្ធិសេរីភាពរបស់គាត់ក្នុងការទទួលបានការស៊ើបអង្កេត និងការជំនុំជម្រះក្តីដោយយុត្តិធម៌។ ហើយការខកខានមិនបានទទួលសិទ្ធិដ៏សំខាន់នេះ នៅក្នុងបរិបទត្រឹមត្រូវរបស់វា បង្កឱ្យមានហានិភ័យប្រែក្លាយសិទ្ធិនេះទៅជាសិទ្ធិមួយដែល "មានតែក្នុងទ្រឹស្តី ឬមានតែឈ្មោះ"[66] ។

20. នៅដំណាក់កាលនេះ មេធាវីការពារមិនអាចសន្និដ្ឋានជាមុនបានថា គម្រោងការណ៍ពុករលួយដែលមានទំហំធំធេងជាក់ស្តែងបែបនេះ ត្រូវបានលុបបំបាត់ចោល ដោយសារតែការដើរចេញដ៏គួរឱ្យឆ្ងល់របស់ប្រធានរដ្ឋបាលពីសាលាជម្រះក្តីនេះបានទេ។ ហើយគេក៏មិនអាចវាយតម្លៃស្ថានភាពនៅក្នុងសុញ្ញាកាសបានដែរ។ ប្រព័ន្ធយុត្តិធម៌កម្ពុជាត្រូវបានគេពិចារណាថា ស្ថិតនៅក្នុងចំណោមប្រព័ន្ធយុត្តិធម៌ដែលពុករលួយបំផុតនៅក្នុងពិភពលោក[67] ហើយបន្ទាប់ពីប្រព័ន្ធទាំងអស់នោះមក អ.វ.ត.ក គឺជាផ្នែកមួយនៃប្រព័ន្ធនេះ។ គួរឱ្យសោកស្តាយបំផុត ដោយសារតែវប្បធម៌នៃអំពើពុករលួយ ដែលមានការរីករាលដាលបែបនេះ អតីតតំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាអាចជាការត្រឹមត្រូវ នៅក្នុងការវាយតម្លៃយ៉ាងធ្ងន់មក

[66] *See* para 14, *supra*.
[67] *See, e.g.*, Transparency International, Global Corruption Report 2008 (ranking Cambodia the world's eighteenth most corrupted country) (available at http://www.transparency.org, visited on September 2008).

លើសាលាជម្រះនេះថា: "ភាពទន់ខ្សោយ និងអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ជាតិ បានឆ្លងដល់ អ.វ.ត.ក ជាង អ.វ.ត.ក ជះឥទ្ធិពលដល់ប្រព័ន្ធក្នុងស្រុកទៅវិញ"[68] ។

21. ក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការចាត់ចែងយុត្តិធម៌ឲ្យបានត្រឹមត្រូវជាទូទៅ និងតុលាការដែលមានលក្ខណៈស្មុគស្មាញដូចជាសាលាក្តីមួយនេះ គឺអាស្រ័យលើការប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋានសុច្ចរិតភាពតឹងរ៉ឹង និងសេរីភាពរួចផុតពីការជះឥទ្ធិពលនយោបាយហួសហេតុមកលើ *បុគ្គលិកសំខាន់ៗទាំងអស់*។ អាស្រ័យហេតុនេះ គោលបំណងចំបងនៃសំណើនេះ គឺដើម្បីធានាចំពោះខ្លួនយើងផ្ទាល់ កូនក្តីរបស់យើង និងសាធារណៈជនថា ចៅក្រម ព្រះរាជអាជ្ញា អ្នកចាត់ចែងរដ្ឋបាល ព្រមទាំងបុគ្គលិកគាំទ្ររបស់ អ.វ.ត.ក ឆ្លើយតបទៅនឹងដ៏ខ្ពស់ និងចាំបាច់បែបនេះ។ មេធាវីការពារសង្ឃឹមថា ក.ស.ច.ស នឹងយកឱកាសនេះជួយដល់យើងទាំងអស់គ្នាក្នុងការកំណត់អត្តសញ្ញាណនៃសមាសភាពពុករលួយនៅក្នុងសាលាក្តីនេះ និងប្រហែលជានឹងត្រួសត្រាយគន្លងរាយប៉ាយនេះ ដើម្បីឆ្ពោះទៅកាន់យុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។

## V. សំណូមពរ

22. អាស្រ័យហេតុនេះ មេធាវីការពារសំណូមពរជាបន្ទាន់ឲ្យ ក.ស.ច.ស ទទួលយកពី អ.ស.ប រាជរដ្ឋាភិបាលកម្ពុជា និង/ឬ អង្គការនានា ឬបុគ្គលទាំងឡាយនូវៈ

ក. លទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង។

ខ. រាល់លិខិតឆ្លើយឆ្លងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង និង

គ. ព័ត៌មានទាំងឡាយលើកឡើងពីអំពើពុករលួយជាស្ថាប័ន ដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុននៅ អ.វ.ត.ក។

ឯកសារ និងព័ត៌មានបែបនេះ គួរតែត្រូវបានបង្ហាញជូនដល់មេធាវីការពារ និងភាគីដ៏ទៃទៀតដែលមានចំណាប់អារម្មណ៍ ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ បន្ថែមលើនេះទៅទៀត មេធាវីការពារសូមគោរពអញ្ជើញ ក.ស.ច.ស ឲ្យស្នើសុំការបើកកិច្ចស៊ើបសួរផ្នែករដ្ឋបាលទៅលើ

---

[68] Yash Gai, as quoted by Sebastian Strangio, 'Corruption may undermine Khmer Rouge justice', 23 February 2009 (available at http://www.eurekastreet.com.au/article.aspx?aeid=11895).

ការចោទប្រកាន់ពីអំពើពុករលួយ ដែលមិនទាន់បានដោះស្រាយនៅក្នុងសាលាក្តីនេះនៅឡើយនោះ[69]។

សហមេធាវីរបស់លោក **នួន ជា**

សុន អារុណ Michiel PESTMAN និង Victor COPPE

[69] *N.B.* The OCIJ has previously taken such action with respect to the disclosure of confidential information. *See* Document No A-260, Inter-Office Memorandum from OCIJ to Office of Administration ('Request for Administrative Inquiry'), 3 March 2009.